**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤.សសរ

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់ នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នានៃខ្ពង់រាបបាតសមុទ្រ កម្ពុជា - ថៃ

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើត អាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៨ ស្ដីពី ការ តែងតាំង សមាសភាពគ្រប់គ្រងដឹកនាំ នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា

www.pheakdeylaw.com

# សំរេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រកម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ:

១- ឯកឧត្តម សុខ អាន រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា ប្រធានកិត្តិយស

២- ឯកឧត្តម បណ្ឌិត ហេង វង្សប៊ុនឆាត, អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជា ឧត្តមទីប្រឹក្សា

៣- ឯកឧត្តម ហូ វិចិត្រ, អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា អនុប្រធាន

៤- ឯកឧត្តម វ៉ា គឹម ហុង, ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ជា អនុប្រធាន

៥- ឯកឧត្តម តែ ដួង តារា, អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា អនុប្រធាន

៦- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការសេដ្ឋកិច្ច ជា សមាជិក

៧- តំណាងឧត្តមនាវីឯក អ៊ុង សំខាន់, មេបញ្ជាការកងទ័ពជើងទឹក ជា សមាជិក

៨- លោក ខៀប សារីវិសិដ្ឋ, ជំនួយការផ្ទាល់ឯកឧត្តម សុខ អាន ជាសមាជិក

៩- លោក ហួន សាភីង, អគ្គនាយករងនៃក្រសួងរៀបចំដែនដី-នគរូបនីយកម្ម និង សំណង់ ជាសមាជិក

១០-លោក ឃួន សុគន្ធា, អនុប្រធាននាយកដ្ឋានទទួលបន្ទុកកិច្ចការច្បាប់ និង ចរចា ជាសមាជិក

**ប្រការ ២.-**

គណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រ កម្ពុជា - ថៃ មានភារៈកិច្ចដូចខាងក្រោម :

(ក) ចរចា-រៀបចំ សន្និសញ្ញា និង គ្រប់ប្រព័ន្ធច្បាប់គ្រប់គ្រង-បទបញ្ញត្តិ-គោលការណ៍-បទដ្ឋានទាំងអស់ដែលពាក់ព័ន្ធដល់ ការអភិវឌ្ឍន៍រួមគ្នានៃធនធានប្រេងកាត រាប់បញ្ចូលទាំងមូលដ្ឋានគ្រឹះ ដែលមានផលប្រយោជន៍ទៅវិញទៅមក និង អាចទទួលយកបានដោយភាគីទាំងពីរ ចំពោះការបែងចែកលើ ការចំណាយ



www.pheakdeylaw.com

និង ផលចំណេញ នៃការធ្វើអាជីវកម្មលើធនធានអ៊ីដ្រូការប៊ួរ ដែលឋិតនៅក្នុងតំបន់ នៃ ការអភិវឌ្ឍន៍រួមគ្នា ដើម្បីដាក់ជូន រាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

(ខ) ចរចា-រៀបចំ សន្ធិសញ្ញាលើការកំណត់បែងចែកព្រំដែនសមុទ្រផ្ទៃក្នុង, ខ្ពង់រាបបាតសមុទ្រ និង តំបន់ឯកសិទ្ធិសេដ្ឋកិច្ច ដែលឋិតនៅចន្លោះនៃការទាមទារអះអាងដែនសមុទ្រ បច្ចុប្បន្នរៀងៗខ្លួនរបស់ប្រទេសទាំងពីរ នៅក្នុងតំបន់ដែលនឹងត្រូវបែងចែកព្រំដែន អនុលោមទៅតាមបណ្តាគោលការណ៍ ទាំងឡាយដែលអាច អនុវត្តបាន នៃច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

(គ) ដូចដែលអ្វីសមស្របទៅនឹងតំរូវការចាំបាច់ គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះត្រូវចុះអង្កេត-ផ្ទៀងផ្ទាត់រួមគ្នាលើ និយាមការ ( កូអ័រដោណេ ) នៃកោះ, ថ្ម, ថ្មប៉ប្រះទឹក,ចំណុចនីមួយៗ និង អ្វីៗទាំងអស់ ដែលមានលក្ខណៈពិសេស និង ចរិតប្រវត្តិសាស្ត្រពាក់ព័ន្ធ ឋិតនៅក្នុងដែនដីគោក និង ដែនសមុទ្រ កម្ពុជា - ថៃ ។

ប្រការ ៣.-

គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះ ត្រូវជួបប្រជុំគ្នាអោយបានទៀងទាត់ ក្នុងទស្សនៈសំរេច អោយបាននូវការងាររបស់ខ្លួនទាក់ទងទៅនឹងបញ្ហាទាំងអស់នេះអោយបានឆាប់រួសរាន់ ។ គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះ អាចបង្កើតឡើងនូវអនុគណៈកម្មាធិការ ដូចដែលអ្វីសមស្របទៅនឹងតំរូវការចាំបាច់ ។

ប្រការ ៤.-

គ្រប់សមាជិកនៃគណៈកម្មាធិការបច្ចេកទេសចំរុះនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន ហើយគណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ នឹងត្រូវរាយការណ៍ ជូនរាជរដ្ឋាភិបាលលើលទ្ធផលនៃការងាររបស់ខ្លួន ។

ប្រការ ៥.-

គណៈកម្មាធិការបច្ចេកទេសចំរុះនេះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និង មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។



www.pheakdeylaw.com

**ប្រការ ៦ .-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចំលងជូន</u> :**

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*

*-គ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល*

*- ដូចប្រការ ៦*

*-ឯកសារ-កាលប្បវត្តិ*